**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តបាត់ដំបង**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ :០០៧/១៧ គ.ល.-ខបប

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## សេចក្តីជូនដំណឹង
### ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ

ការងារសាងសង់អគារការិយាល័យច្រកចេញចូលតែមួយ ទំហំ ២១៦ ម² ចំនួន ២ អគារ (នៅក្នុងបរិវេណសាលាស្រុកសង្កែ, សាលាស្រុកថ្មគោល) និងសាងសង់អាគាររដ្ឋបាល ឃុំ សង្កាត់ ចំនួន ៤ អគារ ទំហំ ១២០ ម² (នៅក្នុងបរិវេណឃុំមុខរាហ៍ ឃុំហប់ ឃុំសំពៅលូន និងឃុំគោកឃ្មុំ) ជូនសាលាខេត្តបាត់ដំបង ក្នុងឆ្នាំ ២០១៧

ខេត្តបាត់ដំបង សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ខេត្តបាត់ដំបង នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារសាងសង់អគារការិយាល័យច្រកចេញចូលតែមួយ ទំហំ ២១៦ ម² ចំនួន ២ អគារ (នៅក្នុងបរិវេណសាលាស្រុកសង្កែ, សាលាស្រុកថ្មគោល) និងសាងសង់អាគាររដ្ឋបាល ឃុំ សង្កាត់ ចំនួន ៤ អគារ ទំហំ ១២០ ម² (នៅក្នុងបរិវេណឃុំមុខរាហ៍ ឃុំហប់ ឃុំសំពៅលូន និងឃុំគោកឃ្មុំ) ជូនសាលាខេត្តបាត់ដំបង ក្នុងឆ្នាំ ២០១៧ ។

ខេត្តបាត់ដំបង បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តបាត់ដំបង ដែលមានអាស័យដ្ឋាននៅផ្លូវលេខ ១ ទល់មុខស្ពានថ្មចាស់ ខេត្តបាត់ដំបង ចាប់ពីថ្ងៃទី .០៧.... ខែ សីហា.....ឆ្នាំ ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៥៣ ៧៣២ ៣៧០) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី ...០៥...... ខែ .កញ្ញា.........ឆ្នាំ ២០១៧ វេលាម៉ោង ..១៤:៣០......... ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាស័យដ្ឋានខាងលើ វេលាម៉ោង ១៤:៣០ .......... ថ្ងៃទី .០៥.... ខែ ..កញ្ញា......... ឆ្នាំ ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅបាត់ដំបង, ថ្ងៃទី ០៤...... ខែ សីហា.. ឆ្នាំ ២០១៧

**អភិបាលខេត្ត និងជា**
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ចាន់ សុផល**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ